# យុទ្ធសាស្ត្រវិស័យកសិកម្មនៅកម្ពុជា៖ ជម្រើសអភិវឌ្ឍន៍នៅពេលអនាគត សម្រាប់ផលិតកម្មស្រូវ[១]

## សេចក្តីផ្តើម

ឯកសារនេះ ផ្តោតសំខាន់ទៅលើតួនាទីនៃផលិតកម្មស្រូវក្នុងយុទ្ធសាស្ត្រកសិកម្មនៅកម្ពុជា ។ ដំបូង ឯកសារនេះពិនិត្យពីលទ្ធផលផលិតកម្មស្រូវនៅកម្ពុជា ព្រមទាំងអន្តរាគមន៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលជាប់ទាក់ទងនឹងដំណាំស្រូវ ហើយបន្ទាប់មក កំណត់ពីសក្តានុពល និងឧបសគ្គសម្រាប់ការអភិវឌ្ឍវិស័យនេះនៅពេលអនាគត ។ ដោយគិតគូរដល់យុទ្ធសាស្ត្រកសិកម្មដ៏ធំទូលាយផង ឯកសារនេះនឹងស្រាវជ្រាវថែមទៀតពីជម្រើសនានា និងមាគ៌ាអភិវឌ្ឍន៍ដំណាំស្រូវទៅអនាគត ដោយប្រៀបធៀបស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ទៅនឹងដំណាក់កាលអភិវឌ្ឍន៍ដំបូងនៅប្រទេសជិតខាងទាំងពីររបស់កម្ពុជា គឺ ថៃ និងវៀតណាម ។ ទោះបី ថៃ និងវៀតណាម សុទ្ធតែជាប្រទេសផលិតស្រូវ និងនាំចេញអង្ករក្តី ប៉ុន្តែគេមានយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យស្រូវ ខុសគ្នាគួរឲ្យកត់សម្គាល់ ។ ឯកសារនេះក៏មានផ្តល់មតិពីប្រធានបទមួយចំនួន ឧត្តមភាពប្រៀបធៀបរបស់កម្ពុជាសម្រាប់ធ្វើការស្រាវជ្រាវជាបន្ត ព្រមទាំងស្នើឡើងនូវការសិក្សាប្រៀបធៀបពីមាគ៌ាអភិវឌ្ឍន៍ និងពិពិធកម្ម ក្នុងវិស័យកសិកម្ម ដើម្បីមានជម្រើសកាន់តែច្រើនសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មកម្ពុជានៅពេលអនាគត ។

កម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ដោយមានកំណើនមធ្យមនៃ ផសស (GDP) យ៉ាងលឿនដល់ទៅ ៩,៨% នៅចន្លោះឆ្នាំ២០០០-២០០៨ គឺខ្ពស់ជាងប្រទេសជាច្រើននៅក្នុងតំបន់ (World Bank 2009) ។ នៅអំឡុងពេលជាមួយគ្នានោះ វិស័យកសិកម្មក៏មានលទ្ធផលយ៉ាងល្អ ដោយកើនឡើងជាមធ្យម ៥,៦% ក្នុងមួយឆ្នាំ ។ សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្ម ដែលបានរួមចំណែកប្រមាណមួយភាគបីនៃ ផសស ជាតិ និងប្រើប្រាស់ដល់ជាង ៥០% នៃកម្លាំងពលកម្មសរុប (World Bank 2009) ។

## លទ្ធផល និងគោលនយោបាយជម្រុញផលិតកម្មស្រូវ

ស្រូវជាដំណាំដ៏សំខាន់នៅកម្ពុជា ដោយគ្របដណ្តប់លើផ្ទៃដីដាំដុះអស់ប្រមាណ ៨០% និងជាទំនិញកសិកម្មនាំចេញសំខាន់បំផុត ។ ស្រូវអង្ករ ជាប្រភពចំបងនៃតម្លៃបន្ថែមលើផលដំណាំ និងជាកត្តាចំបងជំរុញកំណើនវិស័យកសិកម្ម ។ វាជាអាហារមូលដ្ឋានក្នុងរបបអាហារជាប្រពៃណី ដោយផ្តល់ជាមធ្យមប្រមាណជាង ៣ភាគ៤ នៃថាមពលស្រូបចូលប្រចាំថ្ងៃរបស់ប្រជាជនធម្មតានៅកម្ពុជា ។ ដូច្នេះស្រូវមានតួនាទីដ៏សំខាន់ ហើយបន្តដើរតួនាទីជាយុទ្ធសាស្ត្រក្នុងកំណើនប្រាក់ចំណូល ការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង នៅកម្រិតគ្រួសារ និងនៅថ្នាក់ជាតិ ។

ដោយទទួលស្គាល់ពីតួនាទីសំខាន់នៃដំណាំស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ ដោយដាក់បញ្ចូលវិស័យនេះក្នុងគ្រប់ឯកសារយុទ្ធសាស្ត្រ និងផែនការរបស់រដ្ឋាភិបាល ដែលមានចែងពីវិស័យកសិកម្ម ។ ការកែលំអទិន្នផលតាមរយៈការធ្វើប្រពលវប្បកម្ម (ដូចជា ការប្រើប្រាស់ជី និងធារាសាស្ត្រ) ជាអាទិភាពទីមួយដើម្បីជំរុញកំណើនវិស័យកសិកម្ម (គឺសំខាន់ជាង ការពង្រីកផ្ទៃដីដាំដុះ) ។ យោងតាមកម្មវិធីគាំទ្រវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្មកម្ពុជា (CAASP) ផលិតកម្មស្រូវត្រូវឡើងដល់ ៦លានតោននៅឆ្នាំ២០១០ និងរំពឹងឡើងដល់ ៧,៥លានតោននៅឆ្នាំ២០២០ (MAFF & MOWRAM 2008) ។ កំណើននេះត្រូវជំរុញឡើងដោយកំណើនទិន្នផលពី ២,៥តោន/ហិកតានៅឆ្នាំ២០០៧ ដល់ ៣,០តោន/ហិកតា នៅឆ្នាំ២០២០ ។ ក្នុងពេលជាមួយគ្នា គេព្យាករណ៍ថា ផ្ទៃដីប្រមូលផលនឹងធ្លាក់ចុះបន្តិច ប៉ុន្តែទំហំផ្ទៃដីស្រោចស្រពនឹងកើនឡើង ២០% ។

ដោយមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល ផលិតកម្មស្រូវបានកើនឡើងគួរឱ្យកត់សម្គាល់តាំងពីឆ្នាំ២០០៣ មក ។ ស្រូវវស្សាគ្មានប្រព័ន្ធស្រោចស្រព រួមចំណែកបានប្រមាណ ៧៥% នៃផលិតកម្មស្រូវសរុប ហើយការរីកចម្រើនផ្នែកស្រូវវស្សា គឺជាកត្តាចំបងក្នុងកំណើនជាងមួយជាពីរនៃទិន្នផលស្រូវ នៅអំឡុងឆ្នាំ១៩៩៤-២០០៨ ។ កំណើនផលិតកម្មស្រូវយ៉ាងលឿននេះបានប្រែក្លាយកម្ពុជា ពីប្រទេសនាំចូលអង្ករសុទ្ធ ទៅជាប្រទេសនាំចេញអង្ករវិញ ។ កម្ពុជាបាននាំចេញអង្ករ ១,៥លានតោនក្នុងឆ្នាំ២០០៧ ដែលរួមចំណែកបាន ១០% នៃតម្លៃនាំចេញសរុបរបស់កម្ពុជា ។ ទោះបីផលិតកម្ម និងការនាំចេញស្រូវអង្ករបានកើនឡើងគួរឱ្យស្ងើចសរសើរក្តី ប៉ុន្តែមានផលិតកម្មស្រូវ

---

១ អត្ថបទនេះរៀបចំឡើងដោយ បណ្ឌិត Bingxin Yu ជាអ្នកស្រាវជ្រាវ និងបណ្ឌិត Xinshen Diao ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) ។ អត្ថបទនេះ ផ្អែកលើឯកសារពិភាក្សាគោលនយោបាយ រៀបចំសម្រាប់កិច្ចប្រជុំបូកសរុប ស្តីពីគោលនយោបាយកសិកម្ម និងសន្តិសុខស្បៀង នៅកម្ពុជា ដែលធ្វើឡើងកាលពីថ្ងៃទី ៤ វិច្ឆិកា ២០១០ ។

តែមួយចំណែកតូចទេ ដែលចូលទៅដល់ទីផ្សារបរទេស ដូច្នេះ នៅទាបជាខ្លាំង បើធៀបនឹងកម្រិតនាំចេញរបស់វៀតណាម និង ថៃ ។

## សក្តានុពលកំណើនស្រូវនាថ្ងៃខាងមុខ និងឧបសគ្គនានា

កម្ពុជា មានសក្តានុពលធំណាស់ដើម្បីបង្កើនផលិតកម្មស្រូវ ។ គេទទួលស្គាល់ជាទូទៅថា កម្ពុជាសំបូរដីកសិកម្ម និង ធនធានទឹក ដែលមិនទាន់បានប្រើប្រាស់ពេញលេញ ពីព្រោះ មានផ្ទៃដីអាចដាំដុះបាន មិនដល់ ៣0% ទេ ដែលគេកំពុងប្រើ សម្រាប់ការដាំដុះ ហើយផ្ទៃដីអាចស្រោចស្រពបាន មានចំនួន ភាគរយកាន់តែតិចជាងនេះទៀត ដែលទទួលការស្រោចស្រព ជាក់ស្តែង (Pech & Sunada, 2008) ។ ដូច្នេះ ការអភិវឌ្ឍ ធារាសាស្ត្រ និងការពង្រីកផ្ទៃដីដាំដុះ អាចជាមធ្យោបាយសាមញ្ញ ជាងគេសម្រាប់បង្កើនផលិតកម្មស្រូវ ។ ផលិតភាព គឺជាប្រភព មួយទៀតនៃសក្តានុពលក្នុងការអភិវឌ្ឍផលិតកម្មស្រូវ ពីព្រោះ ទិន្នផលស្រូវជាមធ្យមនៅកម្ពុជា នៅទាបជាងទិន្នផលនៅ ថៃ និង វៀតណាម ។ ទិន្នផលស្រូវអាចបង្កើនច្រើនទៀតបាន តាមរយៈ ការប្រើប្រាស់បច្ចេកទេសប្រពលវប្បកម្មដំណាំ រាប់បញ្ចូលទាំង ការបង្កើនជីប្រើប្រាស់ និងការកែលំអរបៀបរបបដាំដុះផង ។

ផលិតកម្មស្រូវកម្ពុជាមានសក្តានុពលខ្លាំងក៏ពិតមែន ប៉ុន្តែ កម្ពុជាត្រូវជំនះលើឧបសគ្គជាច្រើនដើម្បីសម្រេចវាបាន ។ តាម ឯកសារមានស្រាប់ គេចាត់ទុកថា ការប្រើប្រាស់ជីមិនគ្រប់គ្រាន់ និងប្រព័ន្ធស្រោចស្រពអន់ខ្សោយ គឺជាឧបសគ្គរាំងស្ទះតឹងតែង ជាងគេ ។ កសិករភាគច្រើននៅកម្ពុជា តែងប្រើជីក្នុងការធ្វើ ស្រែជាទូទៅ ហើយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤ និង ២០០៧ បង្ហាញថា មានការប្រើជីគីមីលើ ៧៧-៧៨% នៃស្រូវវស្សា និង ៨៧-៩៤% នៃស្រូវប្រាំង (តារាង ១) ។ បរិមាណជីប្រើប្រាស់នេះ នៅតិច និងទាបជាង កម្រិតណែនាំសម្រាប់ទូទាំងប្រទេស (Blair & Blair 2010) ។ ដោយផ្អែកលើទិន្នន័យបានពី CSES គួបផ្សំនឹងថ្លៃជាមធ្យម ប៉ាន់ស្មានដែលកសិករបង់លើជី គេគណនាឃើញថានៅឆ្នាំ២០០៤ ការប្រើប្រាស់ជីមានប្រហែល ៧២គ.ក. ក្នុងមួយហិកតា សម្រាប់ ស្រូវវស្សា និង ១០៥គ.ក. ក្នុងមួយហិកតា សម្រាប់ស្រូវប្រាំង ។ កង្វះប្រព័ន្ធស្រោចស្រព ជាឧបសគ្គចំបងមួយទៀតចំពោះការ អភិវឌ្ឍដំណាំស្រូវ ដែលនាំឲ្យវិស័យនេះ ត្រូវពឹងផ្អែកលើ អាកាសធាតុ ។ នៅឆ្នាំ២០០៤ ប្រហែល ១១,៥% នៃផ្ទៃដីស្រែ វស្សា និង ៥០% នៃផ្ទៃដីស្រែប្រាំង ទទួលបានការស្រោចស្រព គ្រប់គ្រាន់ (តារាង ១) ។ នៅឆ្នាំ២០០៧ បរិមាណជីប្រើប្រាស់ និងចំនួនភាគរយផ្ទៃដីស្រែបានស្រោចស្រព មានការថយចុះ ដោយសារអាកាសធាតុអំណោយផល ហើយធាតុចូលឡើងថ្លៃ ខ្ពស់ ។

## ដំណាំស្រូវក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មធំទូលាយ

ដោយសារស្រូវនឹងបន្តដើរតួនាទីសំខាន់ ក្នុងកំណើនកសិកម្មទៅ អនាគតនៅកម្ពុជា ដូច្នេះគេត្រូវដាក់បញ្ចូលផលិតកម្មស្រូវទៅក្នុង បរិបទនៃការអភិវឌ្ឍធំទូលាយ ដើម្បីកំណត់ពីជម្រើសដ៏ប្រសើរ សម្រាប់ការអភិវឌ្ឍថែមទៀត ។ ដំណាំស្រូវមានតួនាទីសំខាន់ ស្រដៀងគ្នាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅថៃ នៅដើមទសវត្សរ៍

តារាង ១៖ ការប្រើប្រាស់ជីនៅកម្ពុជា

| | ស្រូវវស្សា | | ស្រូវប្រាំង | |
|---|---|---|---|---|
| | 2004 | 2007 | 2004 | 2007 |
| ចំណែកនៃក្បាលដី (%) | 86.8 | 84.1 | 14.3 | 15.9 |
| ចំណែកនៃផ្ទៃដីដាំដុះសរុប (%) | 60.9 | 79.2 | 10.8 | 20.7 |
| ក្បាលដីសម្រាប់ដំណាំស្រូវ | | | | |
| ចំណែកនៃក្បាលដីមានប្រើជី (%) | 77.5 | 76.8 | 81.5 | 86.9 |
| ចំណែកនៃផ្ទៃដីមានប្រើជី (%) | 76.9 | 78.5 | 87.2 | 93.5 |
| ចំណាយជាមធ្យមលើជី (រៀល/ហិកតា) | 101,426 | 84,871 | 148,265 | 222,666 |
| ទំហំក្បាលដីជាមធ្យម | 0.9 | 0.9 | 1.0 | 1.3 |
| ថ្លៃជីអ៊ុយរេអន្តរជាតិ (ដុល្លារ/តោន)* | 200 | 415 | 200 | 415 |
| ថ្លៃជីអ៊ុយរេលក់ឲ្យកសិករ (ដុល្លារ/តោន)** | 350 | 600 | 350 | 600 |
| អត្រាប្តូរប្រាក់ជាមធ្យម (រៀល ក្នុង ១ដុល្លារ)*** | 4021 | 4032 | 4021 | 4032 |
| ការប្រើប្រាស់ជីតាមការគណនា (គ.ក./ហិកតា) | 72.1 | 35.1 | 105.4 | 92.0 |
| ចំណែកក្បាលដីមានការស្រោចស្រព (%) | 14.9 | 9.4 | 40.9 | 38.4 |
| ចំណែកផ្ទៃដីមានការស្រោចស្រព (%) | 11.5 | 8.1 | 50.1 | 36.0 |

*កំណត់សម្គាល់៖ បរិមាណជីប្រើប្រាស់ គ្មានរាយការណ៍ក្នុងអង្កេតទេ ។ * IFDC (2008); * * CDRI (2008) ជីអ៊ុយរេ ថ្លៃ 350-510ដុល្លារ/តោន ហើយជីឌីអាម៉ូញ៉ូមផូស្វាត (DAP) ថ្លៃ 450-1080ដុល្លារ/តោន នៅលើទីផ្សារតាមខេត្ត ក្នុងឆ្នាំ2007; * * * IMF (2009)*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ លើទិន្នន័យពី CSES 2004 និង 2007 (វិទ្យាស្ថានជាតិស្ថិតិ)*

ក្រាហ្វិក ១៖ ផសស ក្នុងមនុស្សម្នាក់ គិតតាមថ្លៃប្រាក់ដុល្លារថេរឆ្នាំ២០០០




*កំណត់សម្គាល់៖ តម្លៃនៃខ្សែដេក x គឺ៖ 1 សម្រាប់ឆ្នាំ1997 និង 13 សម្រាប់ឆ្នាំ2009 នៅកម្ពុជា ហើយ 1 សម្រាប់ឆ្នាំ1991 និង 18 សម្រាប់ឆ្នាំ2008 នៅវៀតណាម ហើយនិង ៦ តាងឲ្យឆ្នាំ1960 និង ១៨ តាងឲ្យឆ្នាំ1972 នៅថៃ ។*
*ប្រភព៖ ធនាគារពិភពលោក (2009) ។*

១៩៦០ និង ១៩៧០ នៅវៀតណាម នៅទសវត្សរ៍ ១៩៩០ និងនៅកម្ពុជានាពេលសព្វថ្ងៃ ។ ការប្រៀបធៀបស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ទៅនឹងដំណាក់កាលអភិវឌ្ឍន៍ស្រដៀងគ្នានៅ ថៃ និងវៀតណាម នឹងជួយបង្ហាញពីជម្រើសល្អៗជាក់ស្ដែង សម្រាប់ផលិតកម្មស្រូវនៅកម្ពុជា ។

យើងជ្រើសយកឆ្នាំ១៩៩៧ ជាឆ្នាំដំបូងសម្រាប់ធ្វើការសិក្សាពីកម្ពុជា ដែលពេលនោះមានកម្រិតចំណូលក្នុងមនុស្សម្នាក់ ២៣៩ដុល្លារ (គិតតាមថ្លៃប្រាក់ដុល្លារថេរក្នុងឆ្នាំ២០០០) ។ វៀតណាម សម្រេចបានកម្រិតចំណូលក្នុងមនុស្សម្នាក់ស្រដៀងគ្នានេះក្នុងឆ្នាំ១៩៩១ ។ ចំណូលក្នុងមនុស្សម្នាក់នៅថៃ ឡើងដល់ ៣១៧ដុល្លារ ក្នុងឆ្នាំ១៩៦០ ហើយកម្ពុជាឡើងដល់កម្រិតនេះដែរនៅឆ្នាំ២០០២ ។ ក្រាហ្វិក ១ បង្ហាញពីការប្រៀបធៀប ផសស ក្នុងមនុស្សម្នាក់ សម្រាប់ ៣ ប្រទេសខាងលើ ។ ដើម្បីសម្រួលការប្រៀបធៀបនៅក្នុងក្រាហ្វិក ឆ្នាំទី១ តាងឲ្យឆ្នាំ១៩៩៧ សម្រាប់កម្ពុជា និង ១៩៩១ សម្រាប់វៀតណាម រីឯក្រាហ្វិកសម្រាប់ប្រទេសថៃ ចាប់ផ្ដើមនៅឆ្នាំទី៦ ដែលតាងឲ្យឆ្នាំ២០០២ សម្រាប់កម្ពុជា និង ១៩៦០ សម្រាប់ថៃ ។ កំណើននាពេលថ្មីៗនៅកម្ពុជាគិតតាមចំណូលក្នុងមនុស្សម្នាក់ បានកើនឡើងលឿនជាងនៅថៃ និងវៀតណាម កាលពីពេលដែលប្រទេសទាំងពីរចាប់មានកម្រិតប្រាក់ចំណូលស្រដៀងគ្នានេះដែរ ។ ឧទាហរណ៍ កម្ពុជាសម្រេចបានកម្រិតចំណូលក្នុងមនុស្សម្នាក់ ៣៧០ដុល្លារ នៅឆ្នាំ២០០៤ (ក្នុងរយៈពេល ៧ឆ្នាំ) និង ៥១១ដុល្លារ នៅឆ្នាំ២០០៨ (ក្នុងរយៈពេល ១១ឆ្នាំ) ។ វៀតណាមត្រូវប្រើពេល ៧ឆ្នាំ ដើម្បីបង្កើនចំណូលក្នុងមនុស្សម្នាក់ ពី ២៣៥ដុល្លារ ក្នុងឆ្នាំ១៩៩១ ដល់ ៣៦៥ដុល្លារ ក្នុងឆ្នាំ១៩៩៨ ហើយត្រូវប្រើពេល ១៣ឆ្នាំ ដើម្បីសម្រេចបានចំណូលក្នុងមនុស្សម្នាក់ លើសពី ៥០០ដុល្លារ ។ ការធ្លាក់ចុះសេដ្ឋកិច្ចសាកលនាពេលថ្មីៗ បានពន្យឺតកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៩ ប៉ុន្តែកំណើននេះរំពឹងថានឹងរើបឡើងវិញនៅឆ្នាំ២០១០ និង ២០១១ (ADB 2010) ហើយគម្លាតនៃ ផសស ក្នុងមនុស្សម្នាក់ រវាង កម្ពុជា និងវៀតណាម ទំនងជានឹងរួមចុះនៅទសវត្សរ៍បន្ទាប់ ។ ពិតមែនតែការរើបសេដ្ឋកិច្ចនៅកម្ពុជា អាចថាមិនសូវពឹងផ្អែកខ្លាំងលើស្រូវអង្ករ (ដែលរងការប៉ះពាល់ពីវិបត្តិសាកល តិចជាងវិស័យកាត់ដេរ និងទេសចរណ៍) ប៉ុន្តែវិស័យកសិកម្ម ជាពិសេស ដំណាំស្រូវ នៅតែសំខាន់សម្រាប់កំណើនទៅអនាគតនៅកម្ពុជា ដោយសារមូលហេតុជាច្រើន ។ ការពិនិត្យពីចំណែកនៃវិស័យកសិកម្ម បង្ហាញថា មាគ៌ានៃបំលាស់ប្ដូរស៊ីជំរៅនៅកម្ពុជា វាស្រដៀងគ្នានឹង ថៃ ជាង វៀតណាម ។

ការប្រៀបធៀបទិន្នផលស្រូវបច្ចុប្បន្ននៅកម្ពុជា ថៃ និងវៀតណាម បង្ហាញថា ដំណាំស្រូវកម្ពុជាផ្ដល់ទិន្នផលបានតែពាក់កណ្ដាលនៃទិន្នផលវៀតណាម ប៉ុន្តែគម្លាតរវាងកម្ពុជា និងថៃ មានទំហំតូចត្រឹម ១០% ប៉ុណ្ណោះ ។ គេតែងលើកពីប្រទេសវៀតណាមជារឿយៗ ដើម្បីវែកញែកពីសក្ដានុពលទិន្នផលនៅកម្ពុជា ប៉ុន្តែប្រទេសទាំងពីរមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ក្នុងលក្ខខណ្ឌពីដំបូង ដូច្នេះទិន្នផលស្រូវនៅកម្ពុជាដើរស្របច្រើនជាងតាមលំនាំទិន្នផលនៅថៃ (ក្រាហ្វិក ២) ។

កម្ពុជា គួរយកចិត្តទុកដាក់កាន់តែច្រើនលើបទពិសោធន៍ប្រទេសថៃ ក្នុងការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំស្រូវ ព្រោះ ទីមួយ កម្ពុជា និង ថៃ មានលក្ខខណ្ឌធនធានធម្មជាតិស្រដៀងគ្នា ដោយសារប្រទេសទាំងពីរមានដីសំបូរ បើគិតតាមស្តង់ដាក្នុងតំបន់ ។ ទីពីរ លទ្ធភាពស្រោចស្រព និងអត្រាប្រើប្រាស់ជី មាន

ក្រាហ្វិក ២៖ និន្នាការទិន្នផលស្រូវក្នុង ៣ ប្រទេស (គិតជា តោន/ហិកតា)




*កំណត់សម្គាល់៖ តម្លៃនៃខ្សែដេក x គឺ៖ 1 សម្រាប់ឆ្នាំ1997 និង 13 សម្រាប់ឆ្នាំ2009 នៅកម្ពុជា ហើយ 1 សម្រាប់ឆ្នាំ1991 និង 18 សម្រាប់ឆ្នាំ2008 នៅវៀតណាម ហើយនិង 7 តាងឲ្យឆ្នាំ1961 និង ១៨ តាងឲ្យឆ្នាំ1972 នៅថៃ ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានពី FAO (2010) ។*

កម្រិតទាបនៅថៃ បើធៀបនឹងនៅវៀតណាម ។ ភាពប្រកួតប្រជែងរបស់ថៃលើទីផ្សារអន្តរពិភពលោក មិនជាប់ទាក់ទងខ្លាំងនឹងការកែលំអទិន្នផលទេ ពីព្រោះកំណើនផលិតកម្មថៃផុសចេញពីការពង្រីកផ្ទៃដីផង និងការកែលំអទិន្នផលផង ។ ទីបី លក្ខណៈប្លែកដាច់គេមួយនៃផលិតកម្មស្រូវនៅថៃគឺ ពិពិធកម្មនៃវិស័យនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខុសៗគ្នានៅទីផ្សារបរទេស ។ អង្ករគុណភាពខ្ពស់របស់ថៃ ច្រើនតម្រង់ទិសទៅកាន់ទីផ្សារប្រទេសអភិវឌ្ឍន៍ ឬអ្នកប្រើប្រាស់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលខ្ពស់ រីឯអង្ករថ្លៃទាប បានជួយឲ្យថៃ ជ្រៀតចូលដល់ទីផ្សារអង្ករនៅប្រទេសអាហ្វ្រិកជាច្រើន ។ ប្រភេទស្រូវដែលកម្ពុជាដាំដុះសម្រាប់នាំចេញ ទទួលបានថ្លៃខ្ពស់ដោយសារមានគុណភាព និងរសជាតិល្អ គាប់ចិត្តអ្នកប្រើប្រាស់ក្នុងទីផ្សារកម្រិត

តារាង ២៖ លទ្ធផលពិសោធន៍ពីកំណើនផលស្រូវដោយការពង្រីកផ្ទៃដីដាំដុះ និងការបង្កើនធាតុចូលប្រើប្រាស់

| រដូវ | ផ្ទៃដីបច្ចុប្បន្ន ឬ ការប្រើធាតុចូល | ផលស្រូវបច្ចុប្បន្ន (ពាន់តោន) | ការពង្រីក ផ្ទៃដីដាំដុះ ឬ បង្កើនធាតុចូល (% នៃកម្រិតបច្ចុប្បន្ន) | ការបង្កើនផ្ទៃដី និងការប្រើ ធាតុចូល សាកល្បង (Simulation) | ភាពលុត (Elasticity) នៃផលស្រូវ ដោយកត្តា ដី/ ធាតុចូល | កំណើនផលស្រូវ (តោន) |
|---|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) | (6) |
| ផ្ទៃដីដាំស្រូវ[១] | | | | | | |
| ស្រូវវស្សា | 2,110.0 | 2,828 | 10 | 211.0 | 0.683 | 193,180 |
| ស្រូវប្រាំង | 373.0 | 827 | 10 | 37.0 | 0.625 | 51,678 |
| ការប្រើជី[២] | | | | | | |
| ស្រូវវស្សា | 72.1 | 2,828 | 50 | 108.2 | 0.100 | 141,420 |
| ស្រូវប្រាំង | 105.4 | 827 | 10 | 115.9 | 0.203 | 16,785 |
| ការស្រោចស្រព[៣] | | | | | | |
| ស្រូវវស្សា | 11.5 | 2,828 | 100 | 23.0 | 0.152 | 49,441 |
| ស្រូវប្រាំង | 50.1 | 827 | 10 | 55.1 | 0.213 | 8,823 |

*កំណត់សម្គាល់៖ 1 ផ្ទៃដីដាំស្រូវក្នុងជួរឈរលេខ (1) និង (4) គិតជាពាន់ហិកតា*
*2 ការប្រើជី ក្នុងជួរឈរលេខ (1) និង (4) គិតជា គ.ក./ហិកតា*
*3 ការស្រោចស្រព ក្នុងជួរឈរលេខ (1) និង (4) គិតជាភាគរយនៃផ្ទៃដីដាំដុះសរុប ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ លើទិន្នន័យបានពី CSES 2004, Yu and Fan (2010) and FAO (2010)*

ខ្ពស់ ។ បទពិសោធន៍នៅថៃ បានផ្ដល់គំនិតថា ជាជាងខំជំរុញផលិតភាពដែលងាយវាស់វែងតាមរយៈទិន្នផលនោះ យុទ្ធសាស្ត្រដំណាំស្រូវរបស់កម្ពុជា គួរប្រឹងប្រែងបង្កើនភាពប្រកួតប្រជែងតាមការស្វែងរកឱកាសនាំចេញ ដូចជា ការតម្រង់រកទីផ្សារសម្រាប់ប្រភេទស្រូវជាក់លាក់ និងការដាំដុះប្រភេទស្រូវខុសៗគ្នា សម្រាប់អ្នកប្រើប្រាស់ប្រភេទខុសៗគ្នានៅក្រៅប្រទេស ។

លទ្ធផលនៃការពិសោធមួយ ដែលផ្ទែកលើការប៉ាន់ស្មានពីការឆ្លើយតបនៃផ្នែកផ្គត់ផ្គង់ ទៅនឹង កំណើនការប្រើប្រាស់ធាតុចូល និងការពង្រីកផ្ទៃដីដាំដុះ ក៏បានបញ្ជាក់ច្បាស់ពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជាដែរ ដោយបង្ហាញថា តាមស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ការពង្រីកផ្ទៃដីដាំដុះអាចបង្កើនផលស្រូវបានច្រើនជាងកំណើនការប្រើប្រាស់ធាតុចូលទំនើប។លទ្ធផលបង្ហាញទៀតថា ឧត្តមភាពប្រៀបធៀបនៃផលិតកម្មស្រូវនៅកម្ពុជាពឹងផ្អែកលើធនធានដីដ៏សំបូរ ដូច្នេះគោលនយោបាយផ្ដោតលើទិន្នផលស្រូវតែម៉្យាង អាចមិនមែនជាមធ្យោបាយដ៏សក្ដិសិទ្ធិបំផុត ជួយឱ្យដំណាំស្រូវហុចផលចំណេញកាន់តែច្រើនដល់កសិករនោះឡើយ ។

## ការស្រាវជ្រាវទៅអនាគតសម្រាប់យុទ្ធសាស្ត្រកសិកម្ម

ដោយសារកម្ពុជា មានស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯងនៅកម្រិតទូទាំងប្រទេស តាំងពីចុងទសវត្សរ៍ ១៩៩០ ដូច្នេះការបន្តផ្ដោតលើការបង្កើនផលិតកម្មស្រូវ អាចបង្កការផ្គត់ផ្គង់ស្រូវលើស និងការបាត់បង់ឱកាសចូលទីផ្សារស្រូវអង្ករមានតម្លៃខ្ពស់ និងដំណាំមានតម្លៃខ្ពស់ផ្សេងៗទៀត ។ គួរមានការស្រាវជ្រាវច្រើនទៀត ផ្ដោតលើបញ្ហាថា តើកម្ពុជាអាចទាញយកផលចំណេញយ៉ាងដូចម្ដេច ពីឧត្តមភាពប្រៀបធៀបរបស់ខ្លួនតាមការនាំចេញអង្ករមានគុណភាព និងតម្លៃបន្ថែមខ្ពស់ ។ សំខាន់គេត្រូវពិនិត្យទៅលើការដោះដូរគ្នា (trade-offs) រវាងគោលដៅអភិវឌ្ឍន៍ខុសៗគ្នានៃដំណាំស្រូវ ដូចជា រវាង ការបង្កើនទិន្នផលហើយនិងការអភិវឌ្ឍដំណាំស្រូវគុណភាព ខ្ពស់និងច្រើនប្រភេទជាដើម ។ ម៉្យាងទៀត កម្ពុជាក៏អាចរៀនសូត្រពីបទពិសោធន៍នៅថៃក្នុងការលើកកម្ពស់ការអភិវឌ្ឍ និងការស្រាវជ្រាវកសិកម្មដើម្បីកែលំអគុណភាព និងរសជាតិពូជស្រូវផ្សេងៗ ។ ការស្រាវជ្រាវទាំងនេះ ក៏ត្រូវពិចារណាពីផលប៉ះពាល់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំស្រូវខុសៗគ្នាទៅលើ ភាពក្រីក្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតគ្រួសារដែរ ។

ការស្រាវជ្រាវពីពិពិធកម្មមុខដំណាំ ក៏សំខាន់សម្រាប់យុទ្ធសាស្ត្រកសិកម្មរបស់កម្ពុជាដែរ ។ ដំណាំត្រូវការដីខ្ពស់ ដូចជា ដំឡូង និងពោត អាចផ្ដល់ប្រាក់ចំណូលកាន់តែច្រើនដល់កសិករ ជួយទ្រទ្រង់សន្តិសុខស្បៀងក្នុងតំបន់មួយចំនួន និងពង្រីកមូលដ្ឋានរកប្រាក់ចំណូលពីការនាំចេញទំនិញកសិកម្ម ។ បទពិសោធន៍ និងមេរៀននៅតាមបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ ក៏មានប្រយោជន៍គួរសិក្សាដែរ ។ ការស្រាវជ្រាវពីពិពិធកម្មដំណាំគួរផ្ដោតទៅលើទាំងផលិតកម្ម និងការធ្វើពិពិធកម្ម ។ បទពិសោធន៍នៅប្រទេសអាស៊ីអាគ្នេយ៍នានាបង្ហាញថា ផលិតកម្មស្បៀងមានច្រើនមុខ អាចធ្វើឲ្យការហូបចុកមានអាហារច្រើនមុខដែរ ដែលជួយកែលំអស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារនៅជនបទ ។ ទំនាក់ទំនងរវាងពិពិធកម្មផលិតកម្ម ពិពិធកម្មការហូបចុក និងការកែលំអអាហារូបត្ថម្ភ គួរមានការសិក្សាកាន់តែលម្អិតនៅពេលអនាគត ។

សរុបមក ការអភិវឌ្ឍយុទ្ធសាស្ត្រវិស័យកសិកម្មផ្អែកលើភស្តុតាងជាក់ស្ដែង ត្រូវមានការស្រាវជ្រាវបង្កើនការយល់ដឹងពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជា និងជម្រើសនានាសម្រាប់ស្វែងរកឧត្តមភាពនេះ ។ ត្រូវមានការយល់ដឹងកាន់តែច្បាស់ដែរពីអន្តរកម្មរវាងជម្រើសកំណើនខុសៗគ្នា និងផលប្រយោជន៍នៃកំណើនក្នុងការបង្កើតប្រាក់ចំណូលសម្រាប់អ្នកក្រ និងការកែលំអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ បន្ទាប់មក ត្រូវមានការកំណត់ច្បាស់ពីអាទិភាព និងលំដាប់នៃវិនិយោគសាធារណៈដើម្បីជំរុញកំណើនកសិកម្ម ។

## ឯកសារយោង

ADB (2010), *Asian Development Outlook 2010: Macroeconomic Management beyond the Crisis,* (Mandaluyong City, Philippines: Asian Development Bank)

Blair, G. and N. Blair (2010), Soil Fertility Constraints and Limitations to Fertiliser Recommendations in Cambodia, paper presented at the 19th World Congress of Soil Science, Soil Solutions for a Changing World, 1 - 6 August 2010, Brisbane, Australia

CDRI (2008), Impact of High Food Prices in Cambodia: Survey Report. Phnom Penh, (ambodia: Cambodia Development Resource Institute)

CSES (2004; 20070, Cambodia Socio-Economic Survey (Phnom Penh, Cambodia: National Institute of Statistics)

FAO (2010), FAOSTAT, http://faostat.fao.org/ (accessed September 2010)

IFDC (2008), http://www.eurekalert.org/pub_releases/2008-02/i-wfp021908.php

IMF (2009), *Cambodia: Statistical Appendix,* Country Report No. 09/48 (Washington D.C.: International Monetary Fund)

MAFF & MOWRAM (2008), *Strategy for Agriculture and Water: Cambodian Agricultural and Agribusiness Support Programme* (Phnom Penh, Cambodia: Ministry of Agriculture Forestry and Fisheries and Ministry of Water Resources and Meteorology)

Pech, S. & K. Sunada (2008), Population Growth and Natural Resources Pressures in the Mekong River Basin, *Ambio* 37(3): 219-224

World Bank (2009), *World Development Indicator* (Washington, D.C.: World Bank)

Yu, B. & S. Fan (forthcoming), Rice Production Response in Cambodia.,Agricultural Economics, No. doi: 10.1111/j.1574-0862.2010.00522.x